# សេចក្តីប្រកាសរួម

រាជធានីភ្នំពេញ ថ្ងៃសុក្រ ទី២ ខែឧសភា ឆ្នាំ២០២៥

យើងខ្ញុំជាអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិដែលមានរាយនាមដូចខាងក្រោម អ្នកការពារសិទ្ធិមនុស្ស និងអ្នកតស៊ូមតិសិទ្ធិលើប្រព័ន្ធផ្សព្វផ្សាយ សូមសម្តែងការព្រួយបារម្ភយ៉ាងខ្លាំងទៅនឹងការកើនឡើងនៃការរឹតបន្តឹង និងការគំរាមកំហែងទៅលើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យដែលនៅសេសសល់នៅកម្ពុជា។ បន្ថែមពីលើបញ្ហាប្រឈមជាច្រើនដែលអ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យប្រឈមនឹងរដ្ឋាភិបាល និងតួអង្គដ៏មានឥទ្ធិពល ដែលក្នុងនោះរួមមានការយាយីតាមផ្លូវច្បាប់ ការគំរាមកំហែង ការចាប់ខ្លួន ការដកហូតអាជ្ញាបណ្ណ ការដាក់កំហិត តែឥឡូវនេះពួកគេប្រឈមនឹងការកាត់ផ្តាច់មូលនិធិបន្ថែមទៀត។ ឧបសគ្គហិរញ្ញវត្ថុទាំងនេះ ជាការរារាំងយ៉ាងធ្ងន់ធ្ងរដល់សមត្ថភាពរបស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យក្នុងការបន្តប្រតិបត្តិការរបស់ខ្លួន។ ការកាត់ផ្តាច់មូលនិធិនេះនឹងមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋកម្ពុជា ពីព្រោះការទទួលព័ត៌មានគួរឱ្យទុកចិត្តរបស់ពួកគេនឹងត្រូវបានកាត់បន្ថយ ហើយដំណើរការប្រជាធិបតេយ្យនឹងរងផលប៉ះពាល់។

ក្នុងឱកាសខួបលើកទី៣២ នៃទិវាសេរីភាពសារព័ត៌មានពិភពលោកនៅថ្ងៃទី៣ ខែឧសភា អង្គការសង្គមស៊ីវិលរួមជាមួយដៃគូអភិវឌ្ឍន៍បានប្រារព្ធទិវាដ៏សំខាន់នេះនៅថ្ងៃទី២ ខែឧសភា ក្រោមប្រធានបទ "ការការពារប្រព័ន្ធផ្សព្វផ្សាយឯករាជ្យរបស់កម្ពុជា"។ ព្រឹត្តិការណ៍នេះមានគោលបំណងទាញចំណាប់អារម្មណ៍សាធារណជន និងភាគីពាក់ព័ន្ធចំពោះភាពចាំបាច់បន្ទាន់ដើម្បីការការពារ និងលើកកម្ពស់សំឡេងប្រព័ន្ធផ្សព្វផ្សាយចម្រុះដែលចាំបាច់សម្រាប់សុខុមាលភាពលទ្ធិប្រជាធិបតេយ្យ ជាពិសេសដើម្បីឆ្លើយតបទៅនឹងការកាត់ផ្តាច់មូលនិធិដែលប្រព័ន្ធផ្សព្វផ្សាយឯករាជ្យបានប្រឈមមុខនាពេលថ្មីៗនេះ។

ប្រធានបទឆ្នាំនេះបង្ហាញពីបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុដែលប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅទូទាំងប្រទេសកម្ពុជាជួបប្រទះទាំងប្រតិបត្តិការនៅថ្នាក់ជាតិ និងសហគមន៍មូលដ្ឋាន។ ការកាត់ផ្តាច់មូលនិធិនេះធ្វើឱ្យស្ថានភាពបច្ចុប្បន្នកាន់តែធ្ងន់ធ្ងរឡើងៗសម្រាប់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងអ្នកសារព័ត៌មានឯករាជ្យ ដែលមានចំនួនតិចរួចទៅហើយនៅក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់កម្ពុជា ក្នុងនោះការរាយការណ៍ស៊ីជម្រៅលើសកម្មភាព និងគោលនយោបាយរបស់អ្នកកាន់អំណាច កាន់តែខ្វះខាត ដោយសារតែអ្នកសារព័ត៌មានតែង ទទួលរងនូវការតបតជាលក្ខណៈប្រព័ន្ធ ។

ក្នុងឆ្នាំ២០២៤ ខេមបូចា បានចងក្រងករណីរំលោភបំពានចំនួន ៤១ករណី ដែលពាក់ព័ន្ធនឹងអ្នកសារព័ត៌មានយ៉ាងតិច៦៤ នាក់។ ការយាយីតាមផ្លូវច្បាប់គឺជារឿងដែលកើតឡើងញឹកញាប់បំផុត ដែលក្នុងនោះមានអ្នកសារ

ព័ត៌មានចំនួន ៥នាក់ ត្រូវបានឃុំខ្លួន និងអ្នកសារព័ត៌មានម្នាក់ ត្រូវបានសម្លាប់ ខណៈពេលកំពុងអនុវត្តការងាររបស់ខ្លួន។ នៅដើមឆ្នាំ២០២៥ អ្នកសារព័ត៌មាន ៣ នាក់ ទៀតត្រូវបានឃុំខ្លួនពីបទញុះញង់ ហើយអ្នកសារព័ត៌មានស៊ើបអង្កេតជនជាតិអង់គ្លេសម្នាក់ដែលបានចំណាយពេលប្រាំឆ្នាំរាយការណ៍អំពីការកាប់បំផ្លាញព្រៃឈើ និងបញ្ហាបរិស្ថាននៅកម្ពុជាត្រូវបានហាមឃាត់មិនអោយចូលមកប្រទេសកម្ពុជាវិញ។

យោងតាមអង្គការអ្នកសារព័ត៌មានគ្មានព្រំដែន (RSF) កម្ពុជាបានជាប់ចំណាត់ថ្នាក់ទី ១២៨ ក្នុងចំណោម ១៨០ប្រទេសក្នុងឆ្នាំ២០១៦ នៅក្នុងសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោក។ ចំណាត់ថ្នាក់នេះបានធ្លាក់ចុះបន្ថែមទៀតដល់ទី១៦១ ក្នុងឆ្នាំ២០២៥ ដែលឆ្លុះបញ្ចាំងពីបរិយាកាសប្រព័ន្ធផ្សព្វផ្សាយដែលបន្តធ្លាក់ចុះរបស់ប្រទេសកម្ពុជា។ ឧទាហរណ៍ ការបិទវិទ្យុសំឡេងប្រជាធិបតេយ្យ (VoD) កាលពីខែកុម្ភៈ ឆ្នាំ២០២៣ ដែលជាសារព័ត៌មានឯករាជ្យមួយក្នុងចំណោមសារព័ត៌មានឯករាជ្យដែលនៅសេសសល់ចុងក្រោយនៅក្នុងប្រទេសកម្ពុជា ហើយកាលពីឆ្នាំ២០២៤ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានចងក្រងករណីដកហូតអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយចំនួនបីផ្សេងទៀតដែលជាការឆ្លើយតបទៅនឹងការផ្សព្វផ្សាយព័ត៌មានរបស់ស្ថាប័នទាំងនោះ។

វិស័យសារព័ត៌មានដើរតួនាទីដ៏សំខាន់ក្នុងការលើកកម្ពស់សិទ្ធិមនុស្ស អភិបាលកិច្ចល្អ និងលទ្ធិប្រជាធិបតេយ្យ ដូច្នេះយើងខ្ញុំដែលជាអង្គការសង្គមស៊ីវិលដែលមានរាយនាមដូចខាងក្រោម និងអ្នកតស៊ូមតិលើសិទ្ធិប្រព័ន្ធផ្សព្វផ្សាយ រួមគ្នាប្តេជ្ញាចិត្តគោរពគោលការណ៍មូលដ្ឋាននៃប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅកម្ពុជា។ ការបន្តធ្លាក់ចុះនៃសេរីភាពសារព័ត៌មានមិនត្រឹមតែរាំងសំឡេងរបស់យើង និងសំឡេងរបស់ប្រជាជនកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបំផ្លាញចំណុចស្នូលសំខាន់នៃលទ្ធិប្រជាធិបតេយ្យរបស់យើងផងដែរ។ យើងខ្ញុំជាអង្គការសង្គមស៊ីវិលសូមអំពាវនាវឱ្យប្រជាជនកម្ពុជាទាំងអស់ចូលរួមទាមទារឱ្យបញ្ឈប់នូវការរឹតបន្តឹងទាំងនេះ និងឈរក្នុងស្មារតីសាមគ្គីភាពដើម្បីគាំទ្រដល់ប្រព័ន្ធផ្សព្វផ្សាយទាំងឡាយណាដែលលើកកម្ពស់ការពិត តម្លាភាព និងគណនេយ្យភាព។

យើងខ្ញុំជាអង្គការសង្គមស៊ីវិល សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធ ចាត់វិធានការដូចខាងក្រោម៖

១. ធានាឱ្យបាននូវបរិយាកាសការងារប្រកបដោយសេរីភាព សុវត្ថិភាព និងសន្តិសុខ ទាំងតាមប្រព័ន្ធអនឡាញ និងដោយផ្ទាល់ សម្រាប់អ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយដើម្បីឱ្យពួកគេអនុវត្តការងារដោយគ្មានការរឹតបន្តឹង ឬការភ័យខ្លាច។

២. ជៀសវាងការចោទប្រកាន់ព្រហ្មទណ្ឌទៅលើអ្នកសារព័ត៌មានពាក់ព័ន្ធនឹងសកម្មភាពបំពេញវិជ្ជាជីវៈរបស់ពួកគេ។

៣. លើកលែងបទចោទដែលកំពុងត្រូវបានប្រើក្នុងការចោទប្រកាន់អ្នកសារព័ត៌មាន ពិនិត្យឡើងវិញចំពោះការកាត់ទោសព្រហ្មទណ្ឌប្រឆាំងនឹងអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស និងស៊ើបអង្កេតដោយហ្មត់ចត់ និងឯករាជ្យរាល់ករណីអំពើហិង្សាទៅលើអ្នកសារព័ត៌មាន។

៤.សូមដោះលែងអ្នកសារព័ត៌មានដែលកំពុងជាប់ឃុំ និងបញ្ឈប់ការប្រើប្រាស់ក្រមព្រហ្មទណ្ឌដើម្បីកាត់ទោសអ្នកសារព័ត៌មានដែលបំពេញការងារស្របច្បាប់របស់ពួកគេ។

៥.បញ្ឈប់រាល់ទម្រង់នៃការយាយីប្រឆាំងនឹងប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មានដែលបានរាយការណ៍អំពីបញ្ហាដែលជាប្រយោជន៍សាធារណៈ ដូចជាសិទ្ធិដីធ្លី ធនធានធម្មជាតិ និងគណនេយ្យភាពរបស់រដ្ឋាភិបាល ដែលជាញឹកញាប់ត្រូវបានគេមើលឃើញថាជា "បញ្ហារសើប"។

៦. បង្កើនការគាំទ្រមូលនិធិសម្រាប់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងអង្គការសង្គមស៊ីវិលដែលផ្តល់ការការពារ និងជំនួយឧបត្ថម្ភបន្ទាន់ដល់អ្នកសារព័ត៌មានដែលជួបបញ្ហាប្រឈម៕

**សេចក្តីប្រកាសរួមនេះ គាំទ្រដោយ៖**

១. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA)

២. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)

៣. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)

៤. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)

៥. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)

៦.បណ្តាញអ្នកសារព័ត៌មានស្ត្រីកម្ពុជា (CFJ)

៧.អង្គការលើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ (CMPO)

៨. បណ្តាញយុវជនកម្ពុជា (CYN)

៩. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)

១០. អង្គការភាពជាដៃគូដើម្បីបរិស្ថាន និងការអភិវឌ្ឍ (PED)

១១. សហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ (IFJ)

១២. Gerakan Media Merdeka (Geramm-Malaysia)

១៣. Centre for Independent Journalism (CIJ)

១៤. Alliance of Independent Journalists (AJI)

១៥. National Union of Journalists of the Philippines (NUJP)

១៦. Association Journalist Timor Leste (AJTL)

១៧. Reporters Without Borders (RSF)